*ករណីសិក្សា*

# សេចក្តីសង្ឃឹមនៅតែមាន!

លោកស្រី **លី ពិសះ**មានអាយុ៣៥ឆ្នាំជាភរិយារបស់លោក **វ៉ា បារាំង** មានអាជីពជាអ្នករកខ្ចីមច័ន្ទ និងលក់ដូរបន្តិចបន្តួចនៅផ្ទះ នៅភូមិដង្កាមក្តាម ឃុំឈើតុំ ស្រុកក្រគរ ស្ថិតនៅខាងត្បូងឈៀងខាងលិចចម្ងាយ៤០គីឡូ ម៉ែត្រពីទីរួមខេត្តពោធិ៍សាត់។

បងស្រីពិសះមានមុខរបរជាអ្នកលក់ចាបហួយ បានរៀបការជាមួយស្វាមីនៅក្នុងឆ្នាំ១៩៩៥។ មកដល់សព្វថ្ងៃនេះគូស្វាមីភរិយានេះមានកូន២នាក់ ។ នៅក្នុងឆ្នាំ២០០៣បងស្រីបានធ្លាក់ខ្លួនឈឺ ហើយបានពិនិត្យឈាមឃើញថាមានផ្ទុកមេរោគអេដស៍ ហើយជាអកុសលកូនទាំង២នេះបានឆ្លងមេរោគអេដស៍ពីម្តាយនិងឪពុក។ បងស្រីលីពិសះជាអ្នកជម្ងឺម្នាក់លាក់មុខមិនប្រាប់អ្នកណាសោះឡើយ។ ទ្រព្យសម្បត្តិរបស់បងស្រីមានទាំងប៉ុន្មានដែលខិតខំប្រឹងប្រែងកន្លងមកបានលក់ព្យាបាលអស់រលីងដែលការព្យាបាលនោះមិនពិតប្រាកដ។ ក្រោយពីបានដឹងដំណឹងថា គ្រួសារបងស្រីនិងកូនទាំង២មានមេរោគអេដស៍ បុគ្គលិកអង្គការបានរកវិធីយ៉ាងណាដើម្បីចូលទៅផ្តល់ប្រឹក្សាពីការថែទាំសុខភាព និងផ្តល់ព័ត៌មានយ៉ាងច្បាស់ពីសេវាថ្នាំប្រឆាំងមេរោគអេដស៍ ជាលទ្ធផលចុងក្រោយបងស្រីបានយល់ព្រមឲ្យបុគ្គលិកអង្គការចូលជួបនិងទទួលការប្រឹក្សា។ នៅឆ្នាំ២០០៦បងស្រីនិងគ្រួសារបានទៅទទួលសេវាព្យាបាលផ្នែករោគឱកាសនិយមនិងថ្នាំប្រឆាំងមេរោគអេដស៍នៅមន្ទីរពេទ្យខេត្តពោធិ៍សាត់ ក្រោមការគាំទ្រថវិកាធ្វើដំណើរពីអង្គការភីស៊ី។




ក្រោយពីបានទទួលសេវាថ្នាំប្រឆាំងមេរោគអេដស៍ នាងខ្ញុំបានយកចិត្តទុកដាក់ក្នុងការលេបថ្នាំ ថែទាំសុខភាព និងបង្កើតមុខរបរឡើងវិញដើម្បីទ្រទ្រង់ជីវភាពរស់នៅ។ នៅក្នុងឆ្នាំ២០១៣នេះ នាងខ្ញុំមានសុខភាពល្អប្រសើរច្រើនជាងមុន ហើយការប្រកបមុខរបរលក់ដូរនៅក្នុងផ្ទះក៏មានការរីកចម្រើនផងដែរ អាចរកចំណូលបានខ្លះដើម្បីទប់នឹងជីវភាពប្រចាំថ្ងៃ។ ឥឡូវនេះអ្នកភូមិនាងខ្ញុំមិនមានការរើសអើងដល់គ្រួសាររបស់នាងខ្ញុំដូចពីមុនទៀតទេ ។ បងស្រីបានបន្តទាំងមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា អនាគតនាពេលឆាប់ៗខាងមុខនេះ បើមានថ្នាំអាចព្យាបាលឲ្យជាសះស្បើយបាន នាងខ្ញុំនិងស្វាមីព្រមទាំងកូនទាំង២ នឹងមានជីវិតរស់នៅបានយូរដើម្បីថែទាំកូន ហើយកូនរបស់នាងខ្ញុំមានសុខភាពល្អនិងមានឱកាសច្រើនទៅសិក្សានិងមានអនាគតល្អ។